# ការនាំយកប្រភេទឈើពីព្រៃ ឬពីទីកន្លែងណាមួយ ទៅដាំនៅកន្លែងផ្សេងមួយទៀត

*ដោយលោក អួន សំអុល អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ចំការព្រៃដាំ*

## ១.សេចក្ដីផ្ដើម

អ្នកឯកទេស Monograph បានបង្ហាញថា យុទ្ធសាស្ត្រ នាំយកប្រភេទឈើពីព្រៃ ឬ ពីទីកន្លែងណាមួយមកផលិត ដើម្បីដាំនៅទីកន្លែងផ្សេងមួយទៀតគឺជាការអភិវឌ្ឍសម្រាប់ឈើព្រៃជាច្រើនប្រភេទដែលបាននឹងកំពុងប្រើប្រាស់។ ដំណើរការនេះ គឺត្រូវបានឲ្យនិយមន័យ និង បកស្រាយផ្សេងៗគ្នាដោយអ្នកវិទ្យាសាស្ត្រព្រៃឈើមួយចំនួន ។ នៅក្នុងវាក្យស័ព្ទដ៏ទូលំទូលាយជាច្រើន ការនាំយកប្រភេទឈើពីព្រៃ ឬ ពីទីកន្លែងណាមួយទៅដាំនៅកន្លែងផ្សេងមួយទៀត គឺជាដំណើរការនៃការនាំយកប្រភេទឈើព្រៃមកធ្វើការគ្រប់គ្រង និង ធ្វើរុក្ខកម្ម។ លោក Harlan (1975) បានមើលឃើញថាដំណើរការនេះនឹងអាចនាំឲ្យមានការផ្លាស់ប្ដូរលក្ខណៈសេនេទិកនៃរុក្ខជាតិ ដើម្បីសម្របទៅនឹងការចង់បានរបស់មនុស្ស និង ប្រព័ន្ធមជ្ឈដ្ឋាន កសិ-អេកូឡូស៊ី (agro-ecosystem). elak Janick (១៩៨២)បានឲ្យនិយមន័យថា ដំណើរការនេះមានពីរគឺការនាំរុក្ខជាតិព្រៃបញ្ចូលទៅក្នុងសកម្មភាព នៃការដាំដុះ និងការនាំយករុក្ខជាតិបែបនេះមកថែទាំទុកដើម្បីគ្រប់គ្រង និងជ្រើសរើសតាមវិធីផ្សេងៗទៀត។ លោក Leakey and Newton (1994) បានចាត់ទុកថា ការនាំយកប្រភេទឈើពីព្រៃ ឬ ពីកន្លែងណាមួយទៅដាំនៅកន្លែងផ្សេងមួយទៀត គឺជាការទំនាក់ទំនងនៃការធ្វើអត្តសញ្ញាណកម្ម និង លក្ខណៈរបស់ប្រភពរុក្ខជាតិទាំងអស់ ដូចជា ការជ្រើសរើសប្រភេទ និង ការគ្រប់គ្រងប្រភពធនធានសេនេទិក ហើយនិងការសាប-បណ្ដុះ និង ការដាំដុះដោយនិរន្តរភាពនៃ





*ការផលិតប្រភេទឈើព្រៃ ក្រញូង (រូបលើ ) និង ប្រភេទឈើព្រៃនាំចូល អាកាស្យា (រូបក្រោម )*

ប្រភេទមួយចំនួន ដើម្បីគ្រប់គ្រងក្នុងប្រព័ន្ធមជ្ឈដ្ឋានអេកូឡូស៊ី។ លោក Wiersum (1996) បានមើលឃើញថា ដំណើរការនេះគឺជាការអនុញ្ញាតឲ្យមានការសម្របខ្លួនចូលរបស់ប្រភេទរុក្ខជាតិមួយចំនួនឆ្ពោះទៅរកភាពជាក់លាក់មួយនៃលក្ខខណ្ឌបរិស្ថានដែលនាំទៅរកការវិវឌ្ឍន៍ដោយមនុស្ស។ លោកMidgley and Turbull (2002) បានយល់ឃើញថាដំណើរ

ការនេះគឺជាការប្រកួតប្រជែងនៃការរុករក និងការលាយបញ្ចូលគ្នានៃប្រភពធនធានសេនេទិកក្នុងព្រៃ ដើម្បីបង្វែរការប្រើប្រាស់ និង ការផលិតសម្រាប់ការកើនឡើងនៃផលប្រយោជន៍សម្រាប់សង្គម។

ដូចនេះ ការនាំយកប្រភេទឈើពីព្រៃ ឬ ពីទីកន្លែងណាមួយទៅដាំនៅកន្លែងផ្សេងមួយទៀត គឺជាដំណើរការបន្តមួយនៅក្នុងចរិតសេនេទិក និង ជាការអនុវត្តលើការដាំដុះដែលត្រូវបានធ្វើឲ្យប្រសើរឡើងជាបន្តបន្ទាប់។ នៅក្នុងលក្ខខណ្ឌសេនេទិក ការផលិតកូនឈើគឺត្រូវបានបង្កើន និង វិវត្តន៍ដោយមនុស្ស និង រួមបញ្ចូលដំណើរការសំខាន់ៗបួនក្នុងចំណោមនោះរួមមានការធ្វើអត្តសញ្ញាណកម្មការផលិត ការគ្រប់គ្រង និង ការសម្របខ្លួននៃប្រភពសេនេទិកនៃប្រភេទឈើ (Simons 1996). ការនាំយកប្រភេទឈើពីព្រៃ ឬ ពីកន្លែងណាមួយ ទៅដាំនៅកន្លែងមួយផ្សេងទៀតគឺដើម្បីបម្រើផលប្រយោជន៍មនុស្សជាទូទៅ តែឧបសគ្គក្នុងដំណើរការនេះគឺដោយសារការនាំយកប្រភេទឈើ ពីកន្លែងមួយទៅដាំនៅកន្លែងមួយទៀតពុំបានប្រៀបធៀបទីតាំង ដាំដុះ ឬ ពុំមានលក្ខណៈអេកូឡូស៊ីដូចគ្នា។

ដំណើរការផលិតកូនឈើ និង ឈានទៅរកការដាំជាចំការនូវប្រភេទឈើដុះលូតលាស់លឿនទាំងក្នុងស្រុក និង ក្រៅស្រុក ដើម្បីធានាបាននូវការប្រើប្រាស់ដោយនិរន្តរភាព និង កាត់បន្ថយការបំផ្លាញ ឬ ការប្រើប្រាស់ព្រៃធម្មជាតិហួសកំរិត។ អ្នកប្រើប្រាស់គ្រាប់ពូជ ជាពិសេសកសិករ ឬ អាចជាក្រុមកសិករនៅតាមបណ្តាមូលដ្ឋាន គឺជាក្រុមគោលដៅដ៏មានសក្តានុពល។ ដូចនេះ ការអប់រំផ្សព្វផ្សាយ ឬ ការបណ្តុះបណ្តាលបច្ចេកទេសលើការបេះប្រមូលគ្រាប់ពូជ ការសំអាត ការថែរក្សាទុកដាក់ ការបណ្តុះគ្រាប់(ការសាប និងរបៀបប្រព្រឹត្តិកម្មគ្រាប់)ការថែរក្សាកូនឈើក្នុងថ្នាល បច្ចេកទេសដាំឈើជាចំការ និង ព័ត៌មាន នៃប្រភេទឈើ រួមទាំងការលើកទឹកចិត្តដល់ក្រុមគោលដៅ និង អ្នកពាក់ព័ន្ធដែលជាអ្នកអភិវឌ្ឍន៍លើវិស័យនេះគឺជាការចាំបាច់។





*ការនាំយកប្រភេទឈើពីព្រៃ (ឈើទាលទឹក-រូបលើ ) និង ពីបរទេស (អាកាស្យាក្រាស៊ីការប៉ា -រូបក្រោម ) មកដាំ*

## ២_គុណសម្បត្តិ និងគុណវិបត្តិនៃការធ្វើ Domestication ប្រភេទឈើ

គុណសម្បត្តិ :ការនាំយកប្រភេទឈើមួយទៅដាំនៅកន្លែងមួយផ្សេងទៀតអាចមានផលប្រយោជន៍ :

– ប្រភេទនោះត្រូវបានអភិរក្សមិនឲ្យបាត់បង់ និងបានពង្រីកបរិមាណនៅកន្លែងដាំដុះជាចំការ

– ឈើដែលដាំរួចបានផ្តល់ផលប្រយោជន៍យ៉ាងច្រើន ដូចជា សេដ្ឋកិច្ច ការប្រើប្រាស់ប្រចាំថ្ងៃ ប្រយោជន៍ផ្សេងទៀត និង កាត់បន្ថយការដាក់សម្ពាធទៅលើព្រៃធម្មជាតិ

– នៅប្រទេសថៃ ម៉ាឡេស៊ី និង ឥណ្ឌូនេស៊ី ផ្នែកឯកជនបានចូលរួមយ៉ាងសកម្មក្នុងវិស័យដាំឈើ ជាពិសេសប្រភេទឈើ ដុះលូតលាស់លឿនសម្រាប់ផ្គត់ផ្គង់រោងចក្រក្រដាសរបស់គេ។

-កសិករដែលដាំឈើជាលក្ខណៈគ្រួសារក៏ជាអ្នកផ្គត់ផ្គង់ ផលិតផលឈើដ៏សំខាន់មួយដែរ



ភាពជោគជ័យនៃការនាំប្រភេទឈើព្រៃពីបរទេសមកដាំ ដោយការសិក្សាពីអេកូឡូស៊ីនៃប្រភេទឈើដាំធៀបនឹង ទីតាំងដាំដុះបានត្រឹមត្រូវ

សម្រាប់រោងចក្រ។

គុណវិបត្តិៈ ការនាំយកប្រភេទឈើមួយទៅដាំនៅកន្លែងមួយផ្សេងទៀតអាចមានគុណវិបត្តិ ឬ ឧបសគ្គ ៈ

- ការសិក្សាពីអេកូឡូស៊ីនៃប្រភេទដែលត្រូវដាំដើម្បីធៀបនឹងតំបន់មួយផ្សេងទៀតដែលត្រូវយកប្រភេទនេះទៅដាំ (Site matching) មិនបានច្បាស់លាស់ នាំឲ្យការដាំមិនបានជោគជ័យទេ។

- ការដាំឈើតែមួយ ឬ តិចប្រភេទនាំឲ្យចំការឈើដែលដាំងាយរងនូវជំងឺរាតត្បាត ហើយមិនអាចទប់ស្កាត់ ឬ ព្យាបាលបាន។

-មានតែប្រភេទឈើដុះលូតលាស់លឿនមួយចំនួនប៉ុណ្ណោះ ត្រូវបានគេយកចិត្តទុកដាក់ ចំណែកប្រភេទដុះលូតលាស់យឺត ឬ យូរ និង ផ្តល់ផលតិចគេមិនសូវយកចិត្តទុកដាក់ទេ។

- ការដាំឈើ ដែលមិនបានគិតគូរពីប្រភពគ្រាប់ពូជឲ្យបានត្រឹមត្រូវនោះមិនទទួលបានលទ្ធផលតាមការគ្រោងទុកទេ។ ឧទាហរណ៍ ប្រទេសវៀតណាមបានជួបនូវបញ្ហានេះរួចហើយ ដូចជាដាំប្រភេទឈើនាំចូល (អាកាស្យា) រួចកើតជំងឺបំផ្លាញចំការឈើទាំងមូល និង ការដាំដើមកៅស៊ូហើយចេញជ័រតិចតួចបំផុត។ ការបំផ្លាញនៃប្រភេទស្រល់ (*P.radiata*)នៅប្រេស៊ីល អាហ្វ្រិកខាងត្បូងញូហ្សេឡែន និងឈីលី ដោយសារជំងឺ ***Dothistro mathat*** គឺជាការបំផ្លាញយ៉ាងធំនៅពេលដែលដើមឈើមានអាយុប្រមាណជា ៥ ឆ្នាំ។



ភាពបរាជ័យនៃការនាំប្រភេទឈើព្រៃពីបរទេសមកដាំ ដោយមិនបានពិភាក្សាពីអេកូឡូស៊ីនៃប្រភេទឈើដាំធៀបនឹងទីតាំងដាំដុះបានត្រឹមត្រូវ

## ៣. បញ្ហាចំបងៗដែលត្រូវគិតគូ

-ការផ្គត់ផ្គង់គ្រាប់ពូជឈើមានគុណភាពសេនេទិចល្អដល់កម្មវិធីដាំឈើគឺជាឧបសគ្គពិបាកដោះស្រាយ

- មុនពេលដាំត្រូវសិក្សាពីលក្ខណៈអេកូឡូស៊ីនៃប្រភេទដែលត្រូវយកទៅដាំ និង អេកូឡូស៊ីទីកន្លែងត្រូវដាំ (Site matching) ឲ្យបានច្បាស់លាស់ ជាពិសេសចំពោះប្រភេទនាំចូលពីបរទេស

- ការបង្កើតចំការពូជ (ប្រភេទក្នុងស្រុកនិងពីបរទេស) សម្រាប់ផ្តល់គ្រាប់ដល់កម្មវិធីដាំឈើគឺជាផ្នែកមួយចាំបាច់នៃការធ្វើ Domestication ប្រភេទឈើ។

- អ្នកមានបទពិសោធន៍ ឬ ជំនាញគ្រាប់ពូជត្រូវផ្តល់ការបណ្តុះបណ្តាលចំណេះដឹងខាងគ្រាប់ពូជដល់អ្នកប្រើប្រាស់គ្រាប់ពូជជាពិសេសកសិករ។

-កសិករអាចដើរតួជាភ្នាក់ងារចែកចាយគ្រាប់ពូជឈើដ៏មានប្រសិទ្ធភាព (Small holders seed distributors) នៅពេលពួកគាត់មានចំណេះដឹងផ្នែកគ្រាប់ពូជ។ នៅប្រទេស តង់ហ្សានី វិធីសាស្ត្រនេះត្រូវបានអនុវត្តបានជោគជ័យ។